# ខ្លឹមសារសង្ខេប

ចំនួនប្រជាពលរដ្ឋចាស់វ័យចាស់ជរានៅរដ្ឋ California កំពុងកើនឡើងយ៉ាងឆាប់រហ័ស និង វិវឌ្ឍន៍នូវនានាភាព។ សហគមន៍ដែលកំពុងដុះពន្លកនៃមនុស្សវ័យចំណាស់ខុសៗគ្នានៅរដ្ឋ California នេះ តំណាងឲ្យស្ត្រីចាស់ជរាដែលនាំទៅដល់លទ្ធភាពងាយរងគ្រោះកាន់តែច្រើនឡើង ដោយសារបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ និង សុខភាពដែលទាក់ទងទៅនឹងការវិវឌ្ឍន៍វ័យចំណាស់ និង តួនាទីរបស់ពួកគាត់ជាអ្នកផ្តល់នូវតំហែទាំ និង រកប្រាក់កម្រៃ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និង វិបត្តិថវិការរដ្ឋដ៏ស៊ីជម្រៅបន្តឲ្យមាននូវហានិភ័យកាន់តែច្រើនឡើងថែមទៀតលើបញ្ហាស្ថានភាពសុខមាលភាព និង សេដ្ឋកិច្ចរបស់ក្រុមស្ត្រីចាស់ជរា ខណៈប្រភពធនធានសហព័ន្ធ និង រដ្ឋសម្រាប់ធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍ឈានចូលវ័យចាស់ជរា និង ពិការភាព ទទួលរងនូវការគម្រាមកំហែងប្រឈមនឹងបញ្ហាការកាត់បន្ថយការងារទ្រង់ទ្រាយធំៗ។ និន្នាការអវិជ្ជមានទាំងនេះ មិនប៉ះពាល់ដល់ក្រុមស្ត្រីចាស់ជរាមួយផ្នែកនោះទេ តែថែមទាំងប៉ះពាល់ដល់យើងគ្រប់គ្នាផងដែរដែលទទួលបាននូវការរក្សានិរន្តភាព ការបង្រៀន ឬ ការទូន្មានពីសំណាក់ស្ត្រីវ័យចាស់ជរាដែលមានដូចគ្នានឹងយើងទាំងអស់គ្នាកំពុងយកចិត្តទុកដាក់ថែរក្សាជនចាស់ជរានៅក្នុងជីវិតរបស់ពួកគាត់ផងដែរ។

នៅក្នុងការទទួលស្គាល់ថា ក្រុមគ្រួសារ សហគមន៍ប្រជាពលរដ្ឋ និង សង្គមសាធារណៈ បានថម្រើនជឿនលឿនពេល ដែលក្រុមស្ត្រីវ័យចំណាស់មានការចម្រើនល្អតលាស់ គឺមូលនីធិរបស់ស្ត្រីនៃរដ្ឋ California បានបង្កើតឡើងគំនិតផ្តួចផ្តើមរបស់ស្ត្រីវ័យចាស់ជរា (Elder Women´s Initiative) នៅក្នុងភាពជាដៃគូជាមួយនឹងទាយជ្ជទានរបស់រដ្ឋ California (California Endowment) វិទ្យាស្ថាន UCSF សម្រាប់សុខភាព & ជនចាស់ជរា និង ប្រព័ន្ធឃោសនាផ្សព្វផ្សាយអាមេរិកាំងថ្មី (New American Media)។ បន្ថែមលើសពីនេះ ដៃគូសហការចំនួនពីរផ្សេងទៀតបានចូលរួមនៅក្នុងគំនិតផ្តួចផ្តើមនេះ៖ គណៈកម្មាការនៃរដ្ឋ California ដែលស្ថិតលើស្ថានភាពនៃការយកចិត្តទុកដាក់ស្ត្រី (California Commission on the Status of Women) និង មជ្ឈមណ្ឌលស្វែងយល់សម្រាប់បញ្ហាការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (Insight Center for Community Economic Development)។ ដោយបានចាប់ផ្តើមឡើងនៅដើមឆ្នាំ2008 គំនិតផ្តួចផ្តើមនេះ ព្យាយាមសម្រេចឲ្យបាននូវគោលដៅកសាងចលនាមួយដែលដឹកនាំដោយក្រុមស្ត្រីវ័យចាស់ជរាជាច្រើន និង សម្ព័ន្ធភាពរបស់ពួកគាត់ និង សម្រាប់គោលនយោបាយផ្លាស់ប្តូរប្រយោជន៍ឲ្យប្រជាពលរដ្ឋនៅ Californians ទាំងអស់ អាចឈានចូលវ័យចាស់ជរាដោយមានសុខមាលភាព សេចក្តីថ្លៃថ្នូរលំនឹងសេដ្ឋកិច្ច និង សុវត្ថិភាព។ ដោយប្រើប្រាស់វិធីសម្រេចជោគជ័យមួយលើមូលដ្ឋានសហគមន៍នោះ គំនិតផ្តួចផ្តើមនេះប្រកាន់យកនូវជំហានដូចតទៅនេះ៖



- នៅរដូវផ្ការីក និង រដូវក្តៅឆ្នាំ2008 វិទ្យាស្ថាន UCSF សម្រាប់បញ្ហាសុខភាព & ជនចាស់ជរា បានអនុវត្តការសិក្សាស្រាវជ្រាវដែលរួមមានវេទិកាជជែកពិភាក្សាក្រុមមនុស្សសំខាន់ៗ ការធ្វើសម្ភាសន៍តាមទូរស័ព្ទនិងដោយផ្ទាល់ជាមួយនឹងក្រុមមេដឹកនាំរដ្ឋនានាលើបញ្ហាជនចាស់ជរា និង ស្ត្រី។ គំហើញនានា បម្រើឲ្យការរៀបចំផែនការណ៍ទិដ្ឋភាពគោលនយោបាយនៃរដ្ឋ California និង វាយតម្លៃលើសក្តានុពលសម្រាប់ភ្ជាប់ទំនាក់ទំនងស្ត្រីវ័យចាស់ជរា និង សម្ព័ន្ធនានារបស់ពួកគាត់នៅក្នុងចលនាមួយឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងដែលមានឥទ្ធិពលជាវិជ្ជមានដែលមានលើការយល់ដឹងរបស់ជនចាស់ជរានៅរដ្ឋ California។
- នៅរដូវស្លឹកឈើជ្រុះនាឆ្នាំ2008 បណ្តាដៃគូផ្តួចផ្តើមគំនិតបានប្រារព្ធធ្វើការឃោសនានៅតាមសហគមន៍នៅ Oakland Fresno និង Los Angeles។ ដំណើរការចូលរួមស្តាប់ទាំងនេះត្រូវបានរៀបចំឡើងដើម្បីនាំមកឲ្យក្រុមស្ត្រីវ័យចំណាស់ និង សម្ព័ន្ធរបស់ពួកគាត់ទាំងអស់គ្នា ពិគ្រោះពិភាក្សាលើបញ្ហានានាដែលពួកគាត់មានបញ្ហាប្រឈម ដើម្បីផ្តោតជាសំខាន់ទៅលើចំណុចខ្លាំងជាច្រើនដែលពួកគាត់ និង សហគមន៍របស់ខ្លួនផ្តល់ និង ដើម្បីត្រួតពិនិត្យមើលលើលទ្ធភាពសម្រាប់កសាងចលនាមួយនៃស្ត្រីវ័យចំណាស់។
- នៅរដូវស្លឹកឈើជ្រុះនាឆ្នាំ2008នេះដែរ មូលនិធិស្ត្រីនៃរដ្ឋ California បានរួមគ្នាជាក្រុមមួយថ្មីដោះស្រាយបញ្ហាជនចាស់ជរា នៅបញ្ហាវិទ្យាស្ថានកិច្ចការគោលនយោបាយស្ត្រីរបស់ខ្លួន កម្មវិធីបណ្តុះបណ្តាលការគាំទ្រគោលនយោបាយដកពិសោធន៍រយៈពេលវែងមួយដែលមានលក្ខណៈល្អិតល្អន់។ ក្រុមថ្មីនេះ បានចូលរួមបណ្តុះបណ្តាលអ្នកគាំទ្រចំនួនប្រាំមួយនាក់សម្រាប់បញ្ហាជនចាស់ជរាលើបង្កើតឲ្យចេញជារូបរាងពិតប្រាកដ និង ការដឹកនាំផ្លាស់ប្តូរកិច្ចការគោលនយោបាយនៅរដ្ឋ California។

របាយការណ៍នេះ បង្ហាញឲ្យឃើញច្បាស់នូវគំហើញនានា ដែលបានបានមកពីការសិក្សាស្រាវជ្រាវលើគំនិតផ្តួចផ្តើមរបស់ស្ត្រី និង ការឃោសនាផ្សព្វផ្សាយ។ របាយការណ៍បញ្ចប់ដោយក្រុមការងារ AGEnda for Action—អនុសាសន៍ជាគន្លឹះ និង ជំហានសកម្មភាពនានាដែលផ្សារភ្ជាប់ជាក់លាក់ដើម្បីបម្រើនៅក្នុងការដឹកនាំអ្នកផ្គត់ផ្គង់ថវិកា ក្រុមអ្នកអ្នកធ្វើកិច្ចការគោលនយោបាយ និង អង្គការសហគមន៍នានានៅក្នុងជំហានឆ្ពោះទៅមុខជាបន្តបន្ទាប់ទៅមុខ។

ជាបឋម របាយការណ៍នេះ គូសបញ្ជាក់នូវចំណុចសំខាន់លើប

ញ្ហាសម្លេងរបស់ក្រុមស្ត្រីវ័យចំណាស់ និង សម្ព័ន្ធរបស់ពួកគាត់ដែលបាននិយាយចេញមកលើបញ្ហាការយល់ដឹងរបស់ពួកគាត់អំពីវ័យចាស់ជរា ដោយផ្តល់យើងនូវទស្សនៈជាវិជ្ជមានអំពីការឈានចូលវ័យចាស់ជរា និង ត្រួសត្រាយផ្លូវសម្រាប់ចលនាដែលបានដឹកនាំដោយក្រុមស្ត្រីវ័យចាស់ជរា ប្រយោជន៍ឲ្យពួកយើងគ្រប់វ័យរបស់នៅមានសុខមាលភាព និង សេចក្តីថ្លៃថ្នូរនៅរដ្ឋ California។  ការឃោសនាផ្សព្វផ្សាយតាមសហគមន៍ បានកំណត់យកបញ្ហាជាអាទិភាពចំនួនប្រាំសម្រាប់ក្រុមស្ត្រីវ័យចាស់ជរា៖

- ការធ្វើឲ្យប្រសើរឡើងលើបញ្ហាអត្ថប្រយោជន៍ សេវាកម្មកម្មវិធី និង បញ្ហាកិច្ចការគោលនយោបាយនៅក្នុងផ្នែកតំហែទាំសុខភាព សេដ្ឋកិច្ច សន្តិសុខសុវត្ថិភាព បញ្ហាផ្ទះសម្បែង និង ការដឹកជញ្ជូនដែលជាតម្រូវការចាំបាច់ជាបន្ទាន់។

- លទ្ធភាពប្រើប្រាស់ការផ្តល់ឲ្យប្រកបដោយសមត្ថភាពតាមលក្ខណៈវប្បធម៌នូវតំហែទាំសុខភាព និង អត្ថប្រយោជន៍សង្គមប្រកបដោយគុណភាព ត្រូវតែទទួលបានការធានា។

- ទិដ្ឋភាពអវិជ្ជមាននៃវ័យចំណាស់របស់សង្គម ត្រូវតែមានការផ្លាស់ប្តូរទៅក្នុងរូបភាពជាវិជ្ជមាន។

- ក្រុមស្ត្រីចាស់ជរា និង ជិតចូលវ័យចាស់ជរា ត្រូវតែទទួលបានការភ្ជាប់ឲ្យចូលរួមនៅក្នុងការកសាងចលនានេះដែលប្រមើលឃើញដោយក្រុមការងារគំនិតផ្តួចផ្តើមស្ត្រីចាស់ជរា។

- ការកសាងចលនា ត្រូវតែមានលក្ខណៈបូករួម ដោយឆ្លងកាត់ឧបសគ្គនានារវាងជំនាន់ និង កសាងស្ពានចម្លងដែលមានសម្ព័ន្ធដែលមិនពិតប្រាកដដូចជាពិតប្រាកដ។

ទីពីរ របាយការណ៍នេះមានជាអាទិ៍: លទ្ធផលត្រឡប់ពីក្រុមមេដឹកនាំនៅរដ្ឋ California ដែលដាក់បញ្ញត្តិ និង គាំទ្រដល់បញ្ហាសំខាន់ៗនៃក្រុមស្ត្រីវ័យចាស់ជរា និង ជិតឈានចូលចាស់ជរា និង ប្រភពធនធានសំខាន់បំផុតនានាដើម្បីលើកឡើងយកមកដោះស្រាយនូវតម្រូវការចាំបាច់របស់ក្រុមប្រជាពលរដ្ឋទាំងនេះ។  វេទិកា និង បទសម្ភាសន៍ទាំងនេះជាមួយនឹងក្រុមអ្នកកសាងគោលនយោបាយ និង គាំទ្រ បានផ្តល់នូវការប្រមើលមើលឃើញសំខាន់ៗជាច្រើនសម្រាប់ស្វែងយល់លើទិដ្ឋភាពគោលនយោបាយ និង ការបង្កើតឡើងនូវចលនាសម្រាប់និងជាមួយក្រុមស្ត្រីវ័យចាស់ជរា និង ជិតឈានចូលដល់វ័យចាស់ជរា និង ក្រុមគ្រួសារ សហគមន៍ និង សង្គមសាធារណៈចម្រុះជំនាន់។

ភាពខ្វះមុខខ្វះក្រោយលើបញ្ហាថវិការបស់រដ្ឋ គម្រាមកំហែងដល់ផលចំណេញដែលបានបង្កើតឡើងដោយផ្នែកនីតិកម្មនាពេលកន្លងមក និង ពេលខាងមុខដែលទាក់ទងនឹងស្ថេរភាពសេដ្ឋកិច្ច និង សុខភាពរបស់ក្រុមស្ត្រីវ័យចាស់ជរា និង បង្កឲ្យមានភាពស្មុគ្រស្មាញដល់ទិដ្ឋភាពគោលនយោបាយនៃរដ្ឋ California។ ការប្រមើលឃើញដោយក្រុមមេដឹកនាំថ្នាក់រដ្ឋអំពីទិដ្ឋភាពគោលនយោបាយដែលផ្តោតលើទំនាក់ទំនងជិតស្និទ្ធចំនួនពីរ គឺកង្វល់ធំៗចំពោះបញ្ហាសុខមាលភាពរបស់ក្រុមស្ត្រីវ័យចាស់ជរា: ស្ថេរភាពសេដ្ឋកិច្ច និង បញ្ហាតំហែទាំសុខភាពដែលអាចលៃលកដោះស្រាយបាន។

នៅក្នុងបញ្ហាទិដ្ឋភាពគោលនយោបាយដែលលក្ខណៈស្មុគ្រស្មាញ និង ក្នុងស្ថានភាពឡើងចុះ មានភាពបន្ទាន់មួយសម្រាប់កិច្ចការនីតិកម្ម និង គោលនយោបាយជាច្រើនដើម្បីធានាសុវត្ថិភាពប្រកបដោយវិជ្ជមានការផ្តល់ឲ្យនូវអត្ថប្រយោជន៍ផ្នែកសុខភាព និង សង្គមសម្រាប់វិបត្តិនៃជម្ងឺរ៉ាំរ៉ៃ តំហែទាំសុខភាពខួរក្បាល ការយកចិត្តទុកលើបញ្ហាផ្ទះសម្បែងនិងតំហែទាំរយៈពេលវែង មានដូចជា សេវាកម្ម ឬ អត្ថប្រយោជន៍តំហែទាំសុខភាពតាមផ្ទះ និង ទ្រទ្រង់នានា។  ក្រុមស្ត្រីវ័យចាស់ជរា និង ជិតឈានចូលវ័យចាស់ជរា គឺជាអ្នកផ្តល់តំហែទាំយ៉ាងសំខាន់ចំពោះមនុស្ស ក្រុមមនុស្សគ្រប់ជាតិសាសន៍ និង គ្រប់វ័យនៅក្នុងរដ្ឋ ដូចជានៅតាមបណ្តារដ្ឋផ្សេងៗទៀតនៅទូទាំងប្រទេស។

ការប្រមើលឃើញជាមុនមួយរបស់ក្រុមមេដឹកនាំថ្នាក់រដ្ឋនោះ គឺការគូសបញ្ជាក់លើបញ្ហាទំនាក់ទំនងតំហែទាំសុខភាពទៅនឹងបញ្ហាថវិកា ការបង្កើតច្បាប់ និង ការធ្វើការងាររបស់ផ្នែកនីតិបញ្ញត្តិនៅ Sacramento ដោយមានទស្សនៈមួយដែលដំណោះស្រាយជាវិជ្ជមានលើបញ្ហាសេដ្ឋកិច្ច គឺទំនងជាស្ថិតនៅតែលតោលលើបញ្ហាច្បាប់តំហែទាំសុខភាពដែលអាចដោះស្រាយបាន។ ជាលទ្ធផល សេក្តីសម្រេចចិត្តលើបញ្ហាគោលនយោបាយដោយក្រុមអ្នកបង្កើតគោលនយោបាយ រួមទាំងក្រុមអ្នកច្បាប់ ពឹងផ្អែកលើការកសាងចលនាប្រកបដោយជោគជ័យសម្រាប់ការគាំទ្ររបស់ក្រុមស្ត្រីវ័យចំណាស់។  ក្រុមអ្នកធ្វើគោលនយោបាយ និង អ្នកគាំទ្រ ជឿជាក់លើគម្រោងការណ៍រយៈពេលវែងមានលក្ខណៈជាយុទ្ធសាស្ត្រ លើមូលដ្ឋាននៃអាទិភាពច្បាស់លាស់នានាដែលមានតម្លៃយ៉ាងខ្លាំងសម្រាប់ជោគជ័យរបស់ក្រុមការងារផ្តួចផ្តើមគំនិតសម្រាប់ក្រុមស្ត្រីវ័យចំណាស់។  អាស្រ័យលើបទពិសោធន៍នានាកន្លងមកដែលបានមកពីសកម្មភាព និង យុទ្ធសាស្ត្រដែលបានបង្កើតឡើងហើយសម្រាប់ការអភិវឌ្ឍន៍ ក្រុមមេដឹកនាំថ្នាក់រដ្ឋបានសង្កត់បញ្ជាក់លើតម្រូវការចាំបាច់សម្រាប់៖

- ការបង្កើតក្រុមការងារចម្រុះដ៏ធំមួយដើម្បីលើកកម្ពស់លើរបៀបវារៈមួយសម្រាប់ជួយដល់ក្រុមស្ត្រីវ័យចំណាស់ និង ជិតឈានចូលវ័យនេះ ទទួលបាននូវស្ថេរភាពតំហែទាំសុខភាព និង សេដ្ឋកិច្ចដែលអាចដោះស្រាយបាន។

- ការដាក់នូវការផ្តោតការយកចិត្តទុកដាក់លើបញ្ហាលើកឡើងនូវតម្រូវការចាំបាច់របស់ក្រុមស្ត្រីដែលមានប្រាក់ចំណូលទាប។

- ការឈានដល់បណ្តាសម្ព័ន្ធភាពនានាដែលមិនបានប្រើប្រាស់ ដូចក្រុមហ៊ុន សហជីពកម្មករ និង ក្រុមហ៊ុនផ្គត់ផ្គង់បុគ្គលិកនៅក្នុងផ្នែកធុរកិច្ចរបស់រដ្ឋទាំងមូល។

- លើកកម្ពស់ដល់ការពិគ្រោះយោបល់រវាងបុគ្គល ឬ ស្ថាប័នពាក់ព័ន្ធទាំងអស់។

ចុងបញ្ចប់ របាយការណ៍នេះ ផ្តល់ឲ្យក្រុមការងារគំនិតផ្តួចផ្តើមសម្រាប់ក្រុមស្ត្រីវ័យចំណាស់ ក្រុមការងារ AGEnda for Action សម្រាប់កសាងចលនាដ៏មានមានឥទ្ធិពលមួយនៅទូទាំងរដ្ឋ ប្រយោជន៍លើកកម្ពស់ស្ថេរភាពនៃបញ្ហាសុខមាលភាព សេចក្តីថ្លៃថ្នូរ និង សេដ្ឋកិច្ចរបស់ក្រុមស្ត្រីវ័យចំណាស់។  ការយល់ដឹងអំពីជីវភាពសម្បូណ៌សប្បាយ និង គតិបណ្ឌិតផ្ទាល់ខ្លួនដែលបានលេចឡើ

ងពីការឃោសនានៅតាមសហគមន៍ និង លទ្ធផលត្រឡប់ដែលបានផ្ដល់ឲ្យដោយក្រុមមេដឹកនាំរដ្ឋតាមកាលវេលា ដែលបែងចែកដើម្បីផ្ដល់ឲ្យនូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់អនុសាសន៍ទាំងបីនេះ។ ជំហានអនុវត្តន៍សកម្មភាពជាច្រើនសម្រាប់អនុវត្តន៍អនុសាសន៍និមួយៗ មានលម្អិតនៅក្នុងរបាយការណ៍។

## អនុសាសន៍ទី1

### សម្រាំង និង កំណត់អាទិភាពក្រុមការងារគំនិតផ្ដួចផ្ដើមសម្រាប់ការងារស្ត្រី ក្រុមការងារ AGEnda for Action ក្រុមស្ត្រីវ័យចាស់ជរា និង ឈានចូលវ័យនេះហើយមានប្រាក់ចំណូលទាប នានាភាព និង អន្តោប្រវេសន៍

ក្រុមការងារគំនិតផ្ដួចផ្ដើមសម្រាប់ស្ត្រីវ័យចំណាស់ អំពាវនាដល់ការការពារ និង ការស្ថាបនាសង្គមសាធារណៈលើបញ្ហាគោលនយោបាយ និង កម្មវិធីនានា ប្រយោជន៍ធានាស្ថេរភាពសេដ្ឋកិច្ច និង សុខភាពរបស់ក្រុមស្ត្រីចាស់ជរា និង ជិតឈានចូលវ័យនេះ។ ក្រុមការងារ AGEnda for Action មាននូវជំហានសំខាន់ៗ និង សេចក្ដីណែនាំពាក់ព័ន្ធនឹងសភាពសំខាន់ចាំបាច់ ប្រយោជន៍ធានាឲ្យបានថា ក្រុមស្ត្រីចាស់ជរា និង ឈានចូលវ័យនេះដែលមានចំណូលទាប ចម្រុះជាតិសាសន៍ ជាជនអន្តោប្រវេសន្ត៍ និង មានប្រាក់ចំណូលទាប ទទួលបាននូវការគោរពនូវសេចក្ដីថ្លៃថ្នូរ គុណភាពជីវិត និង សុវត្ថិភាពវ័យចាស់ជរាប្រកបដោយសុវត្ថិភាពជាមូលដ្ឋាន។ បញ្ហានេះ ត្រូវបានគេរៀបចំឡើងដើម្បីបញ្ជាក់លើចំណុច និង សិទ្ធិរបស់ក្រុមស្ត្រីចាស់ជរានៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តអំពីប្រព័ន្ធគ្រប់គ្រងផ្លូវការ និង ក្រៅផ្លូវការនៃការគាំទ្រ និង វ័យចំណាស់ត្រង់ចំណុចដែលមានការឧបត្ថម្ភដែលពួកគាត់ត្រូវការចាំបាច់។ សកម្មភាពទាំងនេះមានសារៈសំខាន់លើការគាំទ្រ តាមរយៈការបង្កើតប្រព័ន្ធគ្រប់គ្រងសាធារណៈ និង ឯកជនលើបញ្ហាគណនេយ្យភាព និង ទ្រទ្រង់ ដោយរួមបញ្ចូលនូវដៃគូ និង បុគ្គល ឬ ស្ថាប័នពាក់ព័ន្ធជាច្រើនទៀត។ ប្រព័ន្ធគ្រប់គ្រងប្រភេទនេះ បម្រើដល់ការការពារការស្ថិតនៅដាច់ពីគេឯងរបស់ក្រុមស្ត្រីវ័យចំណាស់ និង លើកទឹកចិត្តដល់ការចូលរួមវិភាគទានបន្តបន្ទាប់របស់ពួកគាត់នៅក្នុងក្រុមគ្រួសារ សហគមន៍ និង សង្គមសាធារណៈ។ ក្រុមការងារ AGEnda for Action មានទំនាក់ទំនងទៅនឹងកំណែទម្រង់ផ្នែកសុខភាព ការផ្ដល់តម្លៃទាបចំពោះភាពសំខាន់នៃការគ្រប់គ្រងលើបញ្ហាជម្ងឺរ៉ាំរ៉ៃ ការពង្រឹងជំនួយផ្នែកពេទ្យ និង តំហែទាំសុខភាព ការជួយឧបត្ថម្ភ និង អត្ថប្រយោជន៍រួមគ្នារយៈពេលវែង និង តម្លៃដែលមាន តាមរយៈជម្រើសនានាសម្រាប់ផ្ដល់តំហែទាំសុខភាពសាធារណៈ។

## អនុសាសន៍ទី2

### កិច្ចការងារតាមបែបប្រជាធិបតេយ្យៈ បង្កើតភាពជាអ្នកដឹកនាំ ភ្ជាប់ទំនាក់ទំនងក្រុមស្ត្រីវ័យចាស់ជរា និង ជិតឈានចូលវ័យនេះ និង កសាងសម្ព័ន្ធចម្រុះ

ក្រុមស្ត្រីវ័យចំណាស់ ដោយរួមមានទាំងអ្នកកំពុងឈានចូលវ័យនេះ និង ក្រុមស្ត្រីវ័យចំណាស់ចម្រុះជាតិសាសន៍ និង សហគមន៍ជនអន្តោប្រវេសន៍ ត្រូវទទួលបាននូវការភ្ជាប់ទំនាក់ទំនងជាលក្ខណៈប្រជាពលរដ្ឋ និង មាននូវកាលានុវត្តភាពបណ្ដុះបណ្ដាលលើការគាំទ្រកិច្ចការគោលនយោបាយសម្រាប់ច្រកផ្លូវអភិវឌ្ឍន៍ដ៏ប្រសើរបំផុតឆ្ពោះទៅរកភាពចាស់ជរាដោយសេចក្ដីថ្លៃថ្នូរ និង សុខមាលភាព។ ការសម្រេចបាននូវគោលដៅនានារបស់ក្រុមផ្ដួចផ្ដើមគំនិតរបស់ស្ត្រីវ័យចំណាស់ គ្រាន់តែអាចទទួលការសម្រេចជោគជ័យតាមរយៈការបង្កើតចលនាដែលរួមមាននូវប្រជាពលរដ្ឋដែលរស់នៅរដ្ឋ Californians ទាំងអស់។ ការកសាងក្រុមចម្រុះ និង ចល័តសម្រាប់ការគាំទ្រកិច្ចការគោលនយោបាយ ត្រូវតែឆ្លងកាត់ព្រំដែនរវាងរដ្ឋ ក្រុមអ្នកធ្វើគោលនយោបាយ អ្នកគាំទ្រ អង្គការតាមសហគមន៍ ជំនាន់ និង វប្បធម៌ថ្នាក់មូលដ្ឋាន និង ជាតិទាំងមូល។ កិច្ចប្រឹងប្រែងរួមគ្នាមួយ ត្រូវមានការធ្វើឡើងដើម្បីបានដល់សហគមន៍ប្រជាពលរដ្ឋដែលនៅឆ្ងាយពីគេជាងនេះ និង អនុតំណាង។

## អនុសាសន៍ទី3

### រ៉ាប់រងកម្មវិធីគាំទ្រប្រព័ន្ធឃោសនាផ្សព្វផ្សាយ

យុទ្ធនាការឃោសនាផ្សព្វផ្សាយដែលកំណត់និរន្តភាពមួយ នឹងមានសារៈសំខាន់នៅក្នុងការអញ្ជើញក្រុមស្ត្រីវ័យចាស់ជរានៃរដ្ឋ California ទៅក្នុងការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋ។ វានឹងនៅតែបង្ហាញឲ្យឃើញថាជាស្ត្រីចាស់ជរាប្រកបដោយវិជ្ជមាន តាមរយៈការទទួលស្គាល់នូវការចូលរួមចំណែកដ៏ធំរបស់ស្ត្រីវ័យជរាចំពោះក្រុមគ្រួសារ សហគមន៍ និង សង្គមសាធារណៈយុទ្ធនាការឃោសនាផ្សព្វផ្សាយមួយ នឹងបម្រើឲ្យដល់ការមានឥទ្ធិពលលើក្រុមមនុស្សចាស់ជរា ក្រុមគ្រួសារ និងការគាំទ្ររបស់ពួកគាត់ដែលមានដូចជា ក្រុមអ្នកបង្កើតគោលនយោបាយ តាមរយៈការឲ្យតម្លៃទាបចំពោះ៖

- ការផ្ដល់តម្លៃលើតួនាទីសំខាន់ដែលក្រុមស្ត្រីចាស់ជរា និង ឈានចូលវ័យនេះ បំពេញនៅក្នុងការបង្ហាត់បង្រៀន និង ការពារក្រុមគ្រួសារ និង សហគមន៍របស់ពួកគាត់។
- ការគាំទ្រក្រុមស្ត្រីវ័យចាស់ជរា និង ឈានចូលវ័យនេះ ដែលពួកគាត់បង្កើត និង បន្តរក្សាចំណងទាក់ទងរវាងជំនាន់មួយទៅជំនាន់។
- សកម្មភាពអនុវត្តនៃក្រុមការងារ AGEnda for Action ដើម្បីធានាឲ្យបានថា ក្រុមស្ត្រីនៅរដ្ឋ California អាចចូលវ័យចំណាស់ដែលមានស្ថិរភាពលើបញ្ហាសុខមាលភាព សេចក្ដីថ្លៃថ្នូរ សេដ្ឋកិច្ច និង សុខភាព។

ជោគជ័យនៃក្រុមការងារសម្រាប់សម្រាប់វ័យចំណាស់ មានសារៈសំខាន់ចំពោះបញ្ហាសុខមាលភាពរបស់ ប្រជាពលរដ្ឋ នៅរដ្ឋ California ទាំងអស់។ ក្រុមស្ត្រីវ័យចាស់ជរា គឺជារតនៈសម្បត្តិរបស់សហគមន៍ និង ដើរតួនាទីនៅក្នុងក្រុមគ្រួសារ សហគមន៍ និង សង្គមសាធារណៈ។ នៅពេលដែលក្រុមស្ត្រីវ័យចំណាស់ខិតខំប្រឹងប្រែងយ៉ាងខ្លាំងនោះ ប្រជាពលរដ្ឋនៅរដ្ឋ California ទាំងអស់ដែលនៅទីនោះ ដោយសារតែបញ្ហានេះគឺមិនត្រឹមតែសម្រាប់ក្រុមស្ត្រីវ័យចំណាស់នោះ។ វាមានន័យចំពោះយើងរាល់រូប។